00752824

E131/4/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 11 / 2011
ម៉ោង (Time/Heure): 14 : 15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## អង្គជំនុំជម្រះសាលាដំបូង-អនុស្សរណៈ

សាធារណៈ / Public

កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំធ្វើការកត់សម្គាល់បឋមត្រួសៗជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី (E131/4)

បន្ទាប់ពីអង្គជំនុំជម្រះបានចេញ "ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងពិនិត្យភស្តុតាងនៃសំណុំរឿង០០២" កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E131) រួចមក កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខបានស្នើសុំធ្វើការកត់សម្គាល់បឋមត្រួសៗជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ (ឯកសារ E131/4) ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីធ្វើការកត់សម្គាល់បឋមត្រួសៗមួយ ជំនួសមុខឱ្យបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយដើម្បីសម្តែងទស្សនៈ និងកង្វល់របស់ខ្លួន។ សហមេធាវីយល់ថាទស្សនៈ និងកង្វល់របស់ខ្លួនពុំអាចបញ្ជាក់ឱ្យបានពេញលេញ នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាឡើយ។

នៅក្នុងដីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបាន បញ្ជាក់ថា៖

> "ដោយអនុលោមតាមវិធាន ៨៩ ស្ទួន នៃវិធានផ្ទៃក្នុង សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហមេធាវីនាំមុខ ឬចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ភាគីផ្សេងៗពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាត ឬលើកយកមកពិនិត្យពិចារណាឡើយ"។

សហមេធាវីនាំមុខបានបញ្ជាក់ថាខ្លួនបានដឹងអំពីសំអាងហេតុខាងលើរបស់អង្គជំនុំជម្រះ ប៉ុន្តែទោះជាយ៉ាងណា ខ្លួននៅតែស្នើសុំ "ឱកាសធ្វើការកត់សម្គាល់បឋមត្រួសៗស្តីពីទស្សនៈ និងកង្វល់របស់ដើមបណ្តឹងរដ្ឋប្បវេណី"។ អង្គជំនុំជម្រះសូមបញ្ជាក់ថាពុំមានមូលដ្ឋានគតិយុត្តណាមួយនៅក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក ដែលអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើតាមការស្នើសុំរបស់ខ្លួនឡើយ ទោះបីក្នុងរូបភាពណាក្តី។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

អង្គភាពបកប្រែភាសាពុំចាំបាច់បកប្រែសំណើសុំនេះទៀតទេ ហើយភាគីក៏ពុំចាំបាច់ធ្វើការឆ្លើយតបទៅនឹងសំណើនេះដែរ។

នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E131/4)។